# សំណួរ ចម្លើយ ទាក់ទងនឹង
# ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦

**សំណួរ១ : តើការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ប្រព្រឹត្តទៅនៅពេលណា ? កន្លែងណា ?**

ចម្លើយ : ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ប្រព្រឹត្តទៅចាប់ពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦នៅសាលាឃុំ សង្កាត់ និងនៅតាមភូមិមួយចំនួនក្នុងឃុំ សង្កាត់ដែលបើកធ្វើការជារៀងរាល់ថ្ងៃគិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ពេលព្រឹកចាប់ពីម៉ោង ៧:០០ ដល់ម៉ោង ១១:30 នាទី និងពេលរសៀលចាប់ពីម៉ោង ២:00 ដល់ ៥:៣០ នាទីល្ងាច ។

**សំណួរ២: ក្នុងរយៈពេលចុះឈ្មោះបោះឆ្នោត ៩០ថ្ងៃ តើការដាក់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់មានប៉ុន្មានថ្ងៃ និងនៅតាមភូមិមានប៉ុន្មានថ្ងៃ ?**

ចម្លើយ : ក្នុងរយៈពេលចុះឈ្មោះបោះឆ្នោត៩០ថ្ងៃ ការដាក់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមសាលាឃុំ សង្កាត់មានរយៈពេល ៤៥ថ្ងៃ គឺពីថ្ងៃទី០១ ដល់ថ្ងៃទី២៥ ខែកញ្ញា និងពីថ្ងៃទី១០ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ រីឯការដាក់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមភូមិមួយចំនួននោះមានរយៈពេល៤៥ថ្ងៃ គឺចាប់ពីថ្ងៃទី២៦ ខែកញ្ញា ដល់ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ។

**សំណួរ៣ : តើប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើងទៅ មានចំនួនប៉ុន្មាននាក់?**

ចម្លើយ : តាមការប៉ាន់ស្មាន ប្រជាពលរដ្ឋដែលមានអាយុ ១៨ឆ្នាំឡើងទៅមានចំនួន ៩,៦៦៨,២១៦នាក់ ។

**សំណួរ៤: ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តើប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌអ្វីខ្លះ ?**

ចម្លើយ : ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរ
- មានអាយុ១៨(ដប់ប្រាំបី) ឆ្នាំឡើងទៅគិតដល់ថ្ងៃបោះឆ្នោត
- មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត
- មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត
- ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច។

**សំណួរ៥ : ដើម្បីចុះឈ្មោះបោះឆ្នោត តើប្រជាពលរដ្ឋត្រូវធ្វើដូចម្តេច ?**

ចម្លើយ ៖ ដើម្បីចុះឈ្មោះបោះឆ្នោតបានប្រជាពលរដ្ឋត្រូវ ៖

- ទៅបង្ហាញខ្លួននៅសាលាឃុំ សង្កាត់របស់ខ្លួន ឬទីកន្លែងណាមួយក្នុងឃុំ សង្កាត់ ដែលខ្លួនកំពុងរស់នៅតាមការកំណត់របស់ គ.ជ.ប
- បង្ហាញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតដល់ក្រុមចុះឈ្មោះបោះឆ្នោត
- មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់។

**សំណួរ៦ ៖ តើប្រជាពលរដ្ឋ ឬកម្មករ និយោជិត សិស្ស និស្សិត មន្ត្រីរាជការ នាយ ឬពលទាហានកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ និងព្រះសង្ឃ ឬបព្វជិតសាសនា ដែលកំពុងស្នាក់នៅក្នុងឃុំ សង្កាត់ណាមួយ អាចសុំចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់នោះបានដែរ ឬទេ ?**

ចម្លើយ ៖ អ្នកកំពុងស្នាក់នៅក្នុងឃុំ សង្កាត់ណាមួយ សុទ្ធតែអាចសុំចុះឈ្មោះបោះឆ្នោតនៅក្នុងឃុំ សង្កាត់នោះបានឱ្យតែសាមីខ្លួនបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌសម្រាប់ការចុះឈ្មោះបោះឆ្នោតដូចបានរៀបរាប់ខាងលើ។

**សំណួរ៧ ៖ នៅពេលទៅចុះឈ្មោះបោះឆ្នោត តើប្រជាពលរដ្ឋត្រូវប្រើឯកសារអ្វីខ្លះ?**

ចម្លើយ ៖ នៅពេលទៅចុះឈ្មោះបោះឆ្នោតប្រជាពលរដ្ឋត្រូវប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ។

**សំណួរ៨៖ តើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទណាខ្លះ ដែលអាចយកទៅចុះឈ្មោះបោះឆ្នោតបាន ?**

ចម្លើយ ៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទាំងបីប្រភេទ ទាំងចាស់ទាំងថ្មីក៏អាចយកទៅចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៦ នេះបានដែរ។

**សំណួរ៩ ៖ ប្រសិនបើមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរហើយ ប៉ុន្តែអាសយដ្ឋានក្នុងអត្តសញ្ញាណប័ណ្ណផ្សេងពីលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនសុំចុះឈ្មោះ តើត្រូវធ្វើដូចម្តេចដើម្បីចុះឈ្មោះបោះឆ្នោតបាន ?**

ចម្លើយ ៖ សាមីខ្លួនសុំចុះឈ្មោះត្រូវនាំមកជាមួយនូវសៀវភៅស្នាក់នៅច្បាប់ដើម ឬសៀវភៅគ្រួសារច្បាប់ដើមដែលមានបញ្ជាក់ការស្នាក់នៅក្នុងឃុំ សង្កាត់ ដើម្បីសុំចុះឈ្មោះបោះឆ្នោត។

**សំណួរ១០ ៖ ចុះប្រសិនបើសាមីខ្លួនពុំមានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារទៀតនោះ តើត្រូវធ្វើ ដូចម្តេចដែរ ?**

ចម្លើយ ៖ សុំលិខិតបញ្ជាក់ទីលំនៅសម្រាប់សុំចុះឈ្មោះបោះឆ្នោត ។

**សំណួរ១១៖ តើការសុំលិខិតបញ្ជាក់ទីលំនៅសម្រាប់សុំចុះឈ្មោះបោះឆ្នោតធ្វើដូចម្តេច ?**

ចម្លើយ ៖ សាមីខ្លួនត្រូវទៅជួបអាជ្ញាធរឃុំ សង្កាត់ដោយនាំមកជាមួយនូវអត្ត[illegible]សញ្ជាតិខ្មែរ និងសាក្សី០១រូបដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់[illegible]

**សំណួរ១២: ប្រសិនបើប្រជាពលរដ្ឋខ្មែរពុំទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ នៅពេលទៅសុំចុះឈ្មោះបោះឆ្នោត តើត្រូវធ្វើដូចម្តេចដែរ ?**

ចម្លើយ : ត្រូវទៅសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត ។

**សំណួរ១៣: តើធ្វើដូចម្តេច ដើម្បីសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត?**

ចម្លើយ : សាមីខ្លួនត្រូវមកបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ដើម្បីសុំឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោតដោយនាំមកនូវ ៖

- សំបុត្រកំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្រកំណើតច្បាប់ដើម ឬសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម ឬព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរតាមការទាមទារសញ្ជាតិរបស់ជនបរទេស ឬព្រះរាជក្រឹត្យផ្តល់សញ្ជាតិដោយសញ្ជាតូបនីយកម្មដល់ជនបរទេស ឬសាលក្រមស្ថាពររបស់តុលាការបញ្ជាក់ទទួលស្គាល់ថាសាមីខ្លួននោះកើតពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ ឬឯកសារភស្តុតាងផ្លូវការដែលបញ្ជាក់ថាសាមីខ្លួនកើតមកពីឪពុក ឬម្តាយដែលមានសញ្ជាតិខ្មែរ។
- រូបថតទំហំ ៣ x ៤ចំនួន២សន្លឹក។
- សាក្សី០២រូបដែលមានសិទ្ធិបោះឆ្នោតមានលំនៅឋាន ឬទីសំណាក់ពិតប្រាកដក្នុងឃុំ សង្កាត់ជាមួយ។

**សំណួរ១៤: តើមន្ត្រីចុះឈ្មោះបោះឆ្នោតមានការគិតគូរយ៉ាងណាចំពោះ ព្រះសង្ឃ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ និងជនមានពិការភាព ?**

ចម្លើយ : មន្ត្រីចុះឈ្មោះបោះឆ្នោតផ្តល់អាទិភាពជូន ក្នុងអំឡុងពេលចុះឈ្មោះបោះឆ្នោត ។

**សំណួរ១៥: គេអាចឱ្យអ្នកសុំចុះឈ្មោះបោះឆ្នោតចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត បានប៉ុន្មាននាក់ក្នុងពេលចុះឈ្មោះ ?**

ចម្លើយ: កម្លាំងរក្សាសណ្តាប់ធ្នាប់នឹងសម្រួលអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតម្តង៣នាក់ ឬច្រើនជាងនេះតាមចំនួនការីកុំព្យូទ័រ ។

**សំណួរ១៦: នៅពេលដែលក្រុមចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ចល័តទៅធ្វើការចុះឈ្មោះបោះឆ្នោតនៅតាមភូមិផ្សេងពីភូមិរបស់អ្នកក្នុងឃុំ សង្កាត់ តើអ្នកអាចទៅសុំចុះឈ្មោះបោះឆ្នោតបាន ឬទេ ?**

ចម្លើយ : នៅគ្រប់ពេលក្នុងអំឡុងពេលនៃការចុះឈ្មោះបោះឆ្នោត ក្រុមចុះឈ្មោះបោះឆ្នោតត្រូវទទួលចុះឈ្មោះ អ្នកសុំចុះឈ្មោះបោះឆ្នោតដែលមកពីគ្រប់ភូមិក្នុងឃុំ [illegible] របស់ខ្លួន ទោះបីក្រុមចុះឈ្មោះបោះឆ្នោតនៅទីតាំងភូមិណាមួយក៏ដោយ [illegible]

**សំណួរ១៧: តើអ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវធ្វើដូចម្តេច នៅពេលដែលមន្ត្រីចុះឈ្មោះបោះឆ្នោតប្រាប់ឱ្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ ?**

ចម្លើយ : អ្នកសុំចុះឈ្មោះបោះឆ្នោតត្រូវពិនិត្យមើលឱ្យបានច្បាស់លាស់នូវគ្រប់ទិន្នន័យរបស់ខ្លួនដែលបង្ហាញនៅលើម៉ូនីទ័រកុំព្យូទ័រ ។ ករណីអ្នកសុំចុះឈ្មោះបោះឆ្នោតមិនចេះអក្សរ ឬមើលមិនច្បាស់ គាត់អាចស្នើសុំជំនួយពីអ្នកដទៃបាន ។

**សំណួរ១៨: តើអាចចុះឈ្មោះច្រើនកន្លែងបានឬទេ បើសាមីខ្លួនមានអាសយដ្ឋានច្រើនកន្លែង ?**

ចម្លើយ : ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋាន ឬ/និងទីសំណាក់ច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដែលជាទីតាំងនៃជីវភាពរស់នៅជាក់ស្តែងរបស់ខ្លួននោះ ដើម្បីចុះឈ្មោះបោះឆ្នោត ។

**សំណួរ១៩: តើភាពខុសគ្នារវាងការចុះឈ្មោះបោះឆ្នោតអាណត្តិមុនៗ និងការចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ មានភាពខុសគ្នាដូចម្តេច ?**

ចម្លើយ : ការចុះឈ្មោះបោះឆ្នោតអាណត្តិមុនៗធ្វើឡើងសរសេរដោយដៃ ចំណែកការចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៦ ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ គឺរៀបចំចុះឈ្មោះតាមប្រព័ន្ធកុំព្យូទ័រ ។

**សំណួរ២០: តើការចុះឈ្មោះបោះឆ្នោតថ្មីតាមប្រព័ន្ធកុំព្យូទ័រមានសារប្រយោជន៍អ្វីខ្លះ ?**

ចម្លើយ :

- ការពារកុំឱ្យមានឈ្មោះស្ទួន ឬបាត់ឈ្មោះ
- មានភាពត្រឹមត្រូវនៃទិន្នន័យរបស់អ្នកបោះឆ្នោត
- បង្កើតបានជាបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ មានរូបថតអ្នកបោះឆ្នោតដែលងាយស្រួលក្នុងការផ្ទៀងផ្ទាត់
- រក្សាបានភាពត្រឹមត្រូវ និងសុវត្ថិភាពនៃទិន្នន័យអ្នកបោះឆ្នោត
- ផ្តល់ភាពងាយស្រួលក្នុងការរកឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតតាមប្រព័ន្ធអ៊ីនធឺណិត ។

**សំណួរ២១: តើក្នុងករណីអ្វីខ្លះ ដែលក្រុមចុះឈ្មោះបដិសេធការសុំចុះឈ្មោះ?**

ចម្លើយ : មានករណីមួយចំនួនដូចខាងក្រោម៖

- គ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត
- មិនគ្រប់អាយុបោះឆ្នោតគិតដល់ថ្ងៃបោះឆ្នោត
- មិនមានឯកសារផ្សេងបញ្ជាក់ពីលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់

**សំណួរ២២: នៅពេលក្រុមចុះឈ្មោះបដិសេធការសុំចុះឈ្មោះ តើអ្នកសុំចុះឈ្មោះប្ដឹងទៅណា ?**

ចម្លើយ : អ្នកសុំចុះឈ្មោះមានសិទ្ធិប្ដឹងតវ៉ាទៅក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរយៈពេល ០៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធការសុំចុះឈ្មោះ ។

**សំណួរ២៣: តើក្រុមប្រឹក្សាឃុំ សង្កាត់ដោះស្រាយបណ្ដឹងតាមរបៀបណា?**

ចម្លើយ : បើប្ដឹងក្នុងពេលកំណត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលក្នុងរយៈពេល ០៣ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។ ពេលប្រជុំសម្រេចត្រូវធ្វើកំណត់ហេតុប្រជុំ។ យោងកំណត់ហេតុអង្គប្រជុំសម្រេចក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេចឱ្យស្រង់សេចក្ដីសម្រេចចូលក្នុង ទ.១២០៣ ចំនួន០៣ច្បាប់ ក្នុងនោះប្រគល់ជូនអ្នកប្ដឹង១ច្បាប់ ។

**សំណួរ២៤: នៅពេលក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចបដិសេធលើពាក្យបណ្ដឹង តើអ្នកប្ដឹងអាចប្ដឹងទៅណាទៀត ?**

ចម្លើយ : នៅពេលក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចបដិសេធលើពាក្យបណ្ដឹងអ្នកប្ដឹងមានសិទ្ធិប្ដឹងទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្ដីសម្រេច (ទ.១២០៣)។

**សំណួរ២៥: តើ គ.ជ.ប ត្រូវដោះស្រាយបណ្ដឹងនោះក្នុងរយៈពេលប៉ុន្មានថ្ងៃ ?**

ចម្លើយ : គ.ជ.ប ត្រូវបើកសវនាការជាសាធារណៈសម្រេចលើបណ្ដឹងនោះក្នុងរយៈពេល០៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្ដឹង។

**សំណួរ២៦: បើ គ.ជ.ប បដិសេធនូវពាក្យបណ្ដឹងនោះ តើអ្នកប្ដឹងត្រូវប្ដឹងទៅណាទៀត ?**

ចម្លើយ : បើ គ.ជ.ប បដិសេធនូវពាក្យបណ្ដឹង អ្នកប្ដឹងអាចប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល០៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ ។ ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចលើពាក្យបណ្ដឹងតវ៉ា ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ថ្ងៃ យ៉ាងយូរបន្ទាប់ពីបានទទួលពាក្យបណ្ដឹង ។ សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

**សំណួរ២៧: តើ គ.ជ.ប រៀបចំបញ្ជីបោះឆ្នោតដំបូងដូចម្ដេច ?**

ចម្លើយ : បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់បញ្ជីបោះឆ្នោតក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួចរាល់ គ.ជ.ប ត្រូវបោះពុម្ព និងចាត់ឱ្យផ្សព្វផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូង រួមនឹងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតតាមឃុំ សង្កាត់នីមួយៗ នៅតាមសាលាឃុំ សង្កាត់ និងទីតាំងណាមួយក្នុងឃុំ សង្កាត់ តាមការកំណត់របស់ច្បាប់។

**សំណួរ២៨: តើការមិនផ្សាយបញ្ជីបោះឆ្នោតដំបូងដើម្បីអ្វី ?**

ចម្លើយ ៖ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋអញ្ជើញទៅពិនិត្យផ្ទៀងផ្ទាត់ឈ្មោះ និងទិន្នន័យរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត និងដើម្បីឱ្យប្រជាពលរដ្ឋប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់។

**សំណួរ២៩៖ តើអ្វីទៅជាការប្តឹងតវ៉ាទៅនឹងបញ្ជីបោះឆ្នោតដំបូង?**

ចម្លើយ ៖ ការប្តឹងតវ៉ាទៅនឹងបញ្ជីបញ្ជីបោះឆ្នោតដំបូង អាចធ្វើឡើងអំពីការបាត់ឈ្មោះរបស់អ្នកបោះឆ្នោត ឬមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែកត់ត្រាមិនច្បាស់លាស់ទៅតាមករណីដូចខាងក្រោម ៖

- សាមីអ្នកប្តឹងតវ៉ា បានទៅសុំចុះឈ្មោះបោះឆ្នោតពិតប្រាកដជាមួយនឹង គ.ជ.ប ហើយ ត្រូវបានទទួលចុះឈ្មោះ ប៉ុន្តែបែរជាមិនមានឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោតដំបូង នៃការិយាល័យដែលខ្លួនបានចុះឈ្មោះ ឬបែរជាមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យផ្សេង ឬមានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែបែរជាមិនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ។
- សាមីអ្នកប្តឹងតវ៉ាបានចុះឈ្មោះ និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ប៉ុន្តែឈ្មោះរបស់គាត់ និងទិន្នន័យពាក់ពន្ធ័ដែលគេបានបញ្ចូលទៅក្នុងបញ្ជីបោះឆ្នោតដំបូងមានភាពមិនច្បាស់លាស់ ឬមិនត្រឹមត្រូវតាមព័ត៌មានដែលគាត់បានផ្តល់ឱ្យ ។

**សំណួរ៣០៖ តើអ្វីទៅជាការប្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូង ?**

ចម្លើយ ៖ ការប្តឹងជំទាស់ទៅនឹងបញ្ជីបោះឆ្នោតដំបូងអាចធ្វើឡើងចំពោះបុគ្គលណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដំបូង ៖

- ក្នុងករណីដែលជននោះមិនមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោតដោយសារ ៖
  - មិនមានសញ្ជាតិខ្មែរ
  - មិនទាន់គ្រប់អាយុចុះឈ្មោះបោះឆ្នោតស្របតាមការកំណត់នៃ ច.ប.ត.រ
  - មិនមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំសង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត
  - ស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬត្រូវបានដកសិទ្ធិបោះឆ្នោត ឬវិកលចរិតឬស្ថិតក្រោមអាណាព្យាបាលទូទៅ ដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។
- ក្នុងករណីដែលជននោះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង ។

**សំណួរ៣១៖ តើការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងរួមនឹងបញ្ជីឈ្មោះដែលនឹងត្រូវលុប ចាប់ពីពេលណាទៅ ?**

ចម្លើយ ៖ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូងរួមនឹងបញ្ជីឈ្មោះដែលនឹងត្រូវលុប ចាប់ពីថ្ងៃទី០៣ រហូតដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧។

**សំណួរ៣២: ពេលមិនផ្សាយបញ្ជីបោះឆ្នោតដំបូង មានភាពមិនប្រក្រតីតើប្រជាពលរដ្ឋប្តឹងទៅកន្លែងណា ?**

ចម្លើយ : ប្រជាពលរដ្ឋអាចប្តឹងទៅក្រុមប្រឹក្សាឃុំ សង្កាត់ចាប់ពីថ្ងៃទី៤ ដល់ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៧ ។ ហើយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវប្រជុំសម្រេចក្នុងរយៈពេល ៣ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

**សំណួរ៣៣: ពេលក្រុមប្រឹក្សាឃុំ សង្កាត់ បដិសេធលើបណ្តឹង តើអ្នកប្តឹងអាចប្តឹងទៅណាបន្តទៀត ?**

ចម្លើយ : ពេលក្រុមប្រឹក្សាឃុំ សង្កាត់ បដិសេធលើបណ្តឹង អ្នកប្តឹងមានសិទ្ធិប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ០៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយ គ.ជ.ប ត្រូវបើកសវនាការក្នុងរយៈពេល ០៥ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

**សំណួរ៣៤: ពេល គ.ជ.ប បដិសេធលើបណ្តឹង តើអ្នកប្តឹងអាចប្តឹងទៅណាបន្តទៀត ?**

ចម្លើយ : ពេល គ.ជ.ប បដិសេធលើបណ្តឹង អ្នកប្តឹងអាចប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល០៥ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធរបស់ គ.ជ.ប ហើយក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើពាក្យបណ្តឹងដោយបើកសវនាការជាសាធារណៈយ៉ាងយូរ ១០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។

**សំណួរ៣៥: នៅពេលដោះស្រាយបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងរួចរាល់ តើ គ.ជ.ប ត្រូវធ្វើអ្វីទៀត ?**

ចម្លើយ : នៅពេលដោះស្រាយបណ្តឹងទាក់ទងនឹងបញ្ជីបោះឆ្នោតដំបូងរួចរាល់ គ.ជ.ប ត្រូវកែសម្រួលបញ្ជីបោះឆ្នោតតាមសេចក្តីសម្រេច និងផ្តល់សុពលភាពឱ្យទៅជាបញ្ជីបោះឆ្នោតផ្លូវការ។

**សំណួរ៣៦: តើបញ្ជីបោះឆ្នោតផ្លូវការនេះ មានទិន្នន័យអ្វីខ្លះ ?**

ចម្លើយ : បញ្ជីបោះឆ្នោតផ្លូវការនេះ មានទិន្នន័យខាងក្រោម ៖

- ឈ្មោះ និងលេខកូដរាជធានីខេត្ត
- ឈ្មោះ និងលេខកូដឃុំ សង្កាត់
- ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត
- កូនប្រអប់ និងលេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត
- អត្តលេខអ្នកបោះឆ្នោត
- លេខ អ.ខ ឬ ឯ.អ ប្រើពេលចុះឈ្មោះបោះឆ្នោត
- រូបថតអ្នកបោះឆ្នោត
- នាមត្រកូល និងនាមខ្លួនដែលរៀបចំតាមលំដាប់អក្ខរក្រមខ្មែរ

- ភេទ
- ថ្ងៃ ខែ ឆ្នាំ កំណើត
- លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់នៃអ្នកបោះឆ្នោត

**សំណួរ៣៧: តើបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០១៦សម្រាប់ធ្វើអ្វី ?**

ចម្លើយ : បញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០១៦នេះ សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧។

**សំណួរ៣៨: ប្រសិនបើមានគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ចង់បានបញ្ជីបោះឆ្នោតផ្លូវការ តើត្រូវធ្វើដូចម្ដេច ?**

ចម្លើយ : គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាលនានា អាចសុំបញ្ជីបោះឆ្នោតផ្លូវការច្បាប់ថតចម្លងបាននៅ គ.ជ.ប ដោយបង់ថ្លៃ ។ តម្លៃនេះត្រូវគិតត្រឹមតម្លៃផលិតប៉ុណ្ណោះ ។

**សំណួរ៣៩: តើ គ.ជ.ប ត្រូវផលិតបញ្ជីបោះឆ្នោតផ្លូវការចំនួនប៉ុន្មានច្បាប់?**

ចម្លើយ : គ.ជ.ប ផលិតបញ្ជីបោះឆ្នោតផ្លូវការចំនួន ០៣ច្បាប់ ដោយត្រូវបញ្ជូនទៅ លធ.ខប មួយច្បាប់ទៅសាលាឃុំ សង្កាត់មួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**សំណួរ៤០: បើប្រជាពលរដ្ឋចង់ទៅមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីបោះឆ្នោតផ្លូវការ តើគាត់ត្រូវទៅកន្លែងណា ?**

ចម្លើយ :
- នៅសាលាឃុំ សង្កាត់របស់ខ្លួន នៅលធ.ខប និង
- មើលតាមគេហទំព័ររបស់ គ.ជ.ប (www.voterlist.org.kh)។

**សំណួរ៤១: តើក្នុងការិយាល័យចុះឈ្មោះបោះឆ្នោតមានភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានចូលរួមសង្កេតការណ៍ដែរឬទេ ?**

ចម្លើយ : គ.ជ.ប បានអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងអ្នកសារព័ត៌មាន ចូលរួមសង្កេតការណ៍ នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ទូទាំងប្រទេស។

**សំណួរ៤២: ចំពោះជនណាដែលរារាំងប្រជាពលរដ្ឋមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬបង្កការអុកឡុកក្នុងដំណើរការចុះឈ្មោះបោះឆ្នោត តើត្រូវទទួលទណ្ឌកម្មបែបណាដែរ ?**

ចម្លើយ : យោងមាត្រា១៤២ នៃច.ប.គ.រ ជនណាដែលរាំងប្រជាពលរដ្ឋមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬបង្កការអុកឡុកក្នុងដំណើរការចុះឈ្មោះបោះឆ្នោតត្រូវផាកពិន័យជាប្រាក់ពី ៥,០០០,០០០ (ប្រាំលាន) រៀល ទៅ ២០,០០០,០០០ (ម្ភៃលាន) រៀល ពី គ.ជ.ប ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ។

**សំណួរ៤៣: ចំពោះជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយដង តើជននោះត្រូវទទួលទណ្ឌកម្មដូចម្តេចដែរ ?**

ចម្លើយ : យោងមាត្រា១៤៤ នៃច.ប.ត.រ ជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយដងត្រូវផាកពិន័យជាប្រាក់ពី ១០,០០០(មួយម៉ឺន)រៀល ទៅ ១០០,០០០ (មួយសែន) រៀល ដោយ គ.ជ.ប ។